**សេចក្តីថ្លែងការណ៍រួម**
**សូមធានាឱ្យមាននូវយុត្តិធម៌ សម្រាប់ករណីឃាតកម្មលើអ្នកសារព័ត៌មានម្នាក់**
**នៅខេត្តសៀមរាប**

**ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤**

យើងខ្ញុំជាក្រុមសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម ពិតជាមានការតក់ស្លុតយ៉ាងខ្លាំង ចំពោះករណីឃាតកម្មលើលោក ឈឿង ឈឹង អ្នកសារព័ត៌មាននៃអង្គភាព កម្ពុជាអភិវឌ្ឍន៍ ដែលធ្លាប់រាយការណ៍អំពីបទល្មើសព្រៃឈើ ត្រូវបានបាញ់សម្លាប់ក្នុងខេត្តសៀមរាប។

លោក ឈឹង ដែលមានវ័យ ៦៣ឆ្នាំ ត្រូវបានជនសង្ស័យបាញ់ចំត្រូវពោះ បណ្តាលឱ្យរងរបួសធ្ងន់ នៅថ្ងៃទី៤ ខែធ្នូ ខណៈគាត់កំពុងធ្វើដំណើរតាមផ្លូវស្ថិតក្នុងស្រុកជីក្រែង ខេត្តសៀមរាប។ ដំបូងគាត់ត្រូវបានបញ្ជូនទៅកាន់មណ្ឌលសុខភាពឃុំ ហើយក្រោយមកក៏បានបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែកខេត្ត ជាកន្លែងដែលគាត់បានទទួលការវះកាត់នៅថ្ងៃទី៥ ខែធ្នូ។ ប៉ុន្តែគួរឱ្យសោកស្តាយ លោក ឈឹង ត្រូវបានស្លាប់នៅទាបភ្លឺព្រឹកថ្ងៃទី៧ ខែធ្នូ។ អាជ្ញាធរបានចេញ សេចក្តីប្រកាសព័ត៌មានមួយ ដោយប្រកាសថាពួកគេបានចាប់ខ្លួនជនសង្ស័យម្នាក់ដែលត្រូវបានគេរាយការណ៍ថាបានសារភាពថាការបាញ់ប្រហារមកលើ លោក ឈឹង ដោយសារតែទំនាស់បុគ្គល។

នេះជាករណីឃាតកម្មលើកដំបូងលើអ្នកសារព័ត៌មាននៅកម្ពុជា ចាប់តាំងពីឆ្នាំ២០១៤ មក នៅពេលដែលលោក តាំង ទ្រី ត្រូវបានសម្លាប់ខណៈកំពុងរាយការណ៍អំពីការកាប់ឈើខុសច្បាប់ដូចគ្នានេះ តែយ៉ាងណា ករណីរំលោភបំពានលើអ្នកសារព័ត៌មាន ដែលបានកត់ត្រា ក្នុងឆ្នាំ២០២៤ បានកើនឡើង បើធៀបនឹងឆ្នាំ២០២៣។ ដូច្នេះយើងខ្ញុំសូមស្នើដល់រាជរដ្ឋាភិបាល សូមធានាថា សិទ្ធិរបស់អ្នកសារព័ត៌មានត្រូវបានការពារ។ ការគាបសង្កត់ភាគច្រើនបានសំដៅទៅលើអ្នកសារព័ត៌មានដែលរាយការណ៍ពីបញ្ហារសើប ដូចជាការបំផ្លិចបំផ្លាញបរិស្ថាន ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ និងឧក្រិដ្ឋកម្មក្នុងប្រទេស។

អ្នកសារព័ត៌មានត្រូវការសេរីភាពក្នុងការរាយការណ៍ពីការពិតដោយមិនមានការសងសឹក។ ឃាតកម្មដ៏រន្ធត់នេះ ត្រូវបានគេមើលឃើញថា កើតឡើងបន្ទាប់ពីអ្នកសារព័ត៌មានជារឿយៗរងនូវការគំរាមកំហែងនិងការចាប់ដាក់ពន្ធនាគារ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជារឿយៗឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មាន តែងតែមិនត្រូវបានផ្តន្ទាទោស ដែលធ្វើឲ្យប៉ះពាល់ដល់សេរីភាពសារព័ត៌មានក្នុងប្រទេស ដែលបន្ថែមពីលើករណីថ្មីៗមួយចំនួនដូចជាការបិទស្ថាប័នសារព័ត៌មាន ដឹ ខេមបូឌា ដេលី ក្នុងឆ្នាំ ២០១៧ និងវិទ្យុសំឡេងប្រជាធិបតេយ្យ វីអូឌី នៅឆ្នាំ ២០២៣ និងការបង្ខំលក់ស្ថាប័នសារព័ត៌មានភ្នំពេញប៉ុស្តិ៍ នៅឆ្នាំ២០១៨។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ កម្ពុជាបានបន្តធ្លាក់ចុះរហូតដល់ទៅ៩លេខ ក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោករបស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន ដោយឈរនៅលេខរៀងទី១៥១ ក្នុងចំណោម ១៨០ប្រទេស។

គ្មានអ្នកសារព័ត៌មានណាម្នាក់សមនឹងប្រឈមនឹងសេចក្តីស្លាប់ ដោយសារការងារសារព័ត៌មានរបស់ពួកគេនោះទេ ទោះបីជាពួកគេទាំងនោះធ្វើការឱ្យស្ថាប័នសារព័ត៌មានណាមួយក៏ដោយ ហើយយើងខ្ញុំសូមថ្កោលទោសយ៉ាងដាច់អហង្ការចំពោះអ្នកដែលប្រើអំពើហិង្សា ដើម្បីបំបិទមាត់អ្នកសារព័ត៌មាន។ ការងារសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាសង្គមនេះ មានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងពិភពលោក ជាពិសេសនៅក្នុងប្រទេសដែលពោរពេញដោយព័ត៌មានមិនពិត ដែលត្រូវបានប្រើប្រាស់ដោយរបស់រដ្ឋាភិបាល និងឥស្សរជនជាន់ខ្ពស់។

យើងខ្ញុំសូមអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវធានាថាយុត្តិធម៌ត្រូវតែទទួលបានសម្រាប់លោក ឈឹង ដើម្បីបង្ហាញថាការ បង្កបទឧក្រិដ្ឋទៅលើអ្នកសារព័ត៌មានដែលបំពេញការងាររបស់ពួកគេ នឹងមិនត្រូវបានអត់ឱនឡើយនៅក្នុងប្រទេសកម្ពុជា៕

**សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយៈ**

1. Overseas Press Club of Cambodia ( OPCC )
2. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
3. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ( ខេមបូចា )
4. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ( CCIM )
5. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ( CCHR )
6. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ( COMFREL )
7. Alliance of Independent Journalist ( AJI ) Indonesia
8. Gerakan Media Merdeka ( Geramm )
9. Prachatai ( Thailand )
10. National Union of Journalists of the Philippines
11. Association Journalists Timor-Leste ( AJTL )
12. International Federation of Journalists ( IFJs )
13. អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន ( RSF )
14. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ( ADHOC )